**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ ...........រ.ប.ក

# របាយការណ៍ខែសីហា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែកញ្ញា ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេស រុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ ហេតុធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍

ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ ៖ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

### ខ. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការអប់រំដោយផ្ទាល់

នៅក្នុងខែកក្កដា ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **៧.៩២២**លើក មានអ្នកចូលរួមសរុបចំនួន **៣២៥.៦៥៨**នាក់ (ធៀបនឹងខែកក្កដា មានចំនួន **៤០៨.២៤០**នាក់ គឺមានការថយចុះចំនួន **៨២.៥៨២**នាក់ ស្មើនឹង**២០,២២%** ក្នុងនោះស្ត្រីចំនួន **១៧៥.៦០៨**នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន<br>រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤៣ | ២.១៨៣ | ១.២០៧ | ១៦៧ | ៨.៨៧២ | ៤.៦៣៧ |
| សរុប ក្រសួង ស្ថាប័ន | | ៤៣ លើក | ២.១៨៣ នាក់ | ១.២០៧ នាក់ | ១៦៧ លើក | ៨.៨៧២ នាក់ | ៤.៦៣៧ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៧០២ | ២៥.៩១៧ | ១៥.៣២៥ | ៦ | ១.៦៩៣ | ៨៣៩ |
| ៣ | ខេត្តបាត់ដំបង | ៩០៥ | ៣២.៤៥០ | ១៦.៦២៧ | ៦២៤ | ១៩.១៧៥ | ១០.៣៨៤ |
| ៤ | ខេត្តពោធិ៍សាត់ | | | | | | |
| ៥ | ខេត្តសៀមរាប | ៣៤៩ | ១៦.៩៧៣ | ១១.១០៨ | ២៩ | ៦១៥ | ៣២៣ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.២២៧ | ៣២.៩០៦ | ១៨.១៩៦ | ៥៤១ | ១០.៧៩០ | ៥.៧៦២ |
| ៧ | ខេត្តកំពង់ចាម | ១.៧២៨ | ៩៤.២៥៨ | ៤៨.៨៤៦ | ១.១០២ | ៣៧.១៦០ | ២០.៣៨៥ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ៣៣ | ១.៩៨៨ | ១.០៥៩ | | | |
| ១០ | ខេត្តស្វាយរៀង | | | | ២៨០ | ១០.៤៨៥ | ៥.៦៧៤ |
| ១១ | ខេត្តប៉ៃលិន | | | | | | |
| ១២ | ខេត្តកោះកុង | | | | ៦៣ | ១៨១៥ | ៧៩៣ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ៤៤ | ២៣៨២ | ២០៨៩ | | | |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ៣១ | ១៥៨២ | ៩៤០ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៩ | ១.៨៩២ | ៨១៨ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ១.៧០៩ | ១.១១៣ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១ | ១៥ | ៨ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ២៣ | ២០.៣៦៦ | ៩.២២៨ | | | |
| សរុប រាជធានី-ខេត្ត | | ៥.០៦៦លើក | ២៣២.៤៣៨នាក់ | ១២៥.៣៥៧នាក់ | ២.៦៤៦លើក | ៨២.១៦៥នាក់ | ៤៤.៤០៦នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៧.៩២២ លើក | | ចំនួនមនុស្សសរុប ៣២៥.៦៥៨ នាក់ | | ចំនួនស្ត្រី ១៧៥.៦០៨ នាក់ | |

### ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក អ្នកទស្សនាតាមហ្វេសប៊ុក ២.៨៨៣នាក់។

- **ខេត្តសៀមរាប៖** មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ៨៥លើក
- **ខេត្តព្រៃវែង៖** មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ៥០លើក

**១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បានអញ្ជើញធ្វើជាវាគ្មិនកិត្តិយសក្នុងសន្និសិទសារព័ត៌មាន ស្តីពី ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី។
- **ខេត្តកំពង់ចាម៖** បានចូលរួមជាវាគ្មិនក្នុងវិទ្យុសរុប ០៦លើក៖ ស្នងការរដ្ឋាននគរបាល ០១លើក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០២លើក មន្ទីរកិច្ចការនារី ០២លើក និងមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ០១លើក។

**១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ**

- **ខេត្តត្បូងឃ្មុំ៖** មន្ទីរកិច្ចការនារី បានយកគ្រឿងឧបភោគបរិភោគ និងអាវយឺតជូនគ្រួសារក្រីក្រ និងក្មេងស្រីរងគ្រោះដោយការលោភសេពសន្ថវៈចំនួន ១១គ្រួសារ នៅឃុំវាលមូ្ល ឃុំក្រែក ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក និងបានផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ ការចំណាកស្រុកដោយប្រថុយប្រថាន និងភូមិឃុំ-សង្កាត់មានសុវត្ថិភាព ដោយមានអ្នកចូលរួមសរុប ៥៧នាក់ ស្រី៤២នាក់។
- **ខេត្តកំពង់ចាម៖ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** សហការជាមួយអង្គការ ILO និង LSCW រៀបចំវេទិការសាធារណៈ នៅស្រុកចំការលើ និងស្រុកកំពង់សៀម មានអ្នកចូលរួមសរុប ៤៣២នាក់ ស្រី២៤៦នាក់។
- **ខេត្តកណ្តាល៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈ ការចុះជួបសំណេះសំណាលសួរសុខទុក្ខគណៈគ្រប់គ្រងវិទ្យាល័យ លោកគ្រូ អ្នកគ្រូ ចំនួន០៦វិទ្យាល័យក្នុងខេត្ត ដោយមានអ្នកចូលរួមសរុប ៧៨៤នាក់ ស្រី៣១៧នាក់។
- **ខេត្តសៀមរាប៖**
  - មន្ទីរអប់រំយុវជន និងកីឡា សហការជាមួយអង្គការ APLE រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពី ការស្វែងយល់អំពីកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ចំនួន០៤លើក មានអ្នកចូលរួមសរុប ៧០០នាក់(ស្រី៤០០នាក់)។
  - **មន្ទីរទេសចរណ៍ខេត្ត៖** បានចុះពង្រឹង និងទប់ស្កាត់ការជួញដូរមនុស្សមនុស្ស ក្នុងវិស័យទេសចរណ៍ នៅតាមអាជីវកម្មស្នាក់នៅ ម៉ាស្សានិងស្ប៉ា ឌីស្កូតែកនិងKTV បៀហ្គាឌិន បានចំនួន **១២ លើក** ដែលមានអ្នកចូលរួមសរុប ៩១នាក់ ស្រី ៧៦នាក់។
- **អង្គការដំណក់ទឹក (ខេត្តបន្ទាយមានជ័យ)៖** បានចុះធ្វើបណ្ណាល័យចល័ត នៅភូមិប៉ោយប៉ែត សង្កាត់ប៉ោយប៉ែត និងភូមិសូរិយា សង្កាត់និមិត្ត អប់រំដល់កុមារស្តីពី សិទ្ធិកុមារទាំងបួន ការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្សព្វផ្សាយពីសេវារបស់អង្គការតំណក់ទឹក អ្នកចូលរួមសរុបចំនួន ១៦៦នាក់ ស្រី៩៦នាក់។

**១.៥. ការផ្សព្វផ្សាយរបស់អង្គការដៃគូ**

- **អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប)៖** ធ្វើការផ្សព្វផ្សាយដល់សហគមន៍ បានចំនួន ១១លើក មានអ្នកចូលរួមសរុប ៥០០នាក់(ស្រី១៧០នាក់)។

- **អង្គការមូលនិធិអេ២១ អង្គការដំណក់ទឹក និងអង្គការសេហ្វហេវិន (ខេត្តបន្ទាយមានជ័យ)៖** ធ្វើការអប់រំផ្សព្វផ្សាយដល់កុមារតាមដងផ្លូវស្តីពី សិទ្ធិកុមារនិងការការពារខ្លួនពីការកេងប្រវ័ញ្ចផ្សេងៗ ការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្សព្វផ្សាយពីសេវារបស់អង្គការ ចំនួន ០៥លើក មានអ្នកចូលរួមចំនួន ២៨១នាក់ ស្រី១៣៥នាក់។

**២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍**(IEC)

- **អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ)៖** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ពលករ ចំនួន ២.៥៣៦នាក់ (ស្រី១.០៥៦នាក់) កុមារ ៣០៧នាក់ (កុមារី ១៥៥នាក់)។
- **អង្គការសាម៉ារីតាន់ភឺស (ខេត្តបាត់ដំបង)៖** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ពលករ ចំនួន ២១៦ច្បាប់។
- **អង្គការមូលនិធិអ២១(ខេត្តសៀមរាប)៖** បានធ្វើការចែកជូនសម្ភារជាសៀវភៅស្តីពី កិច្ចការពារខ្លួនពីការជួញដូរ និងប័ណ្ណរាយការណ៍ពីករណីអំពើជួញដូរមនុស្ស សរុបចំនួន ៥៨០ឈុត។

**៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ**

- **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការចុះអធិការកិច្ចជនបរទេសបានចំនួន **៧៨**សហគ្រាស ពិនិត្យឃើញមានជនបរទេសចំនួន **៤៧០**នាក់(ស្រី**១៣១**នាក់) ក្នុងនោះអ្នកមានប័ណ្ណនិងសៀវភៅការងារ ៤១៩នាក់(ស្រី**១១៣**នាក់) និងគ្មានប័ណ្ណនិងសៀវភៅការងារ ចំនួន ៥១នាក់(ស្រី១៨នាក់)។

**៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **១៧៦.៧៣២**នាក់(ស្រី**៧៨.៤០៣**នាក់) អនីតិជន **១.៧២៥**នាក់(ស្រី៦៤៤នាក់)៖
    - ស្របច្បាប់ ចំនួន **១២១.៣៦៤**នាក់(ស្រី**៥៤.៩០៣**នាក់) អនីតិជន **៣៩១**នាក់(ស្រី**១៦៤**នាក់)
    - មិនស្របច្បាប់ចំនួន **៥៤.៤៤៤**នាក់(ស្រី**២៣.១៣៣**នាក់) អនីតិជន **១.២១៩**នាក់(ស្រី**៤៤០**នាក់)
    - ដាច់ការទាក់ទងចំនួន **៩២៤**នាក់(ស្រី**៣៨៧**នាក់) អនីតិជន **១១៥**នាក់(ស្រី**៤០**នាក់)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១០២.៤៦០**នាក់(ស្រី**៤៥.៣៨៥**នាក់) អនីតិជន **៤៣៤**នាក់ (ស្រី **១៥២**នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន ០១លើក មនុស្សចំនួន **២១**នាក់ (ស្រី០៩នាក់) អនីតិជន ០១នាក់ រួចបានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេសទៀត។

**៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលក្រចេះ តាកែវ កំពង់ធំ កែប កំពង់ចាម ស្វាយរៀង ស្ទឹងត្រែង និងខេត្តសៀមរាប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន **២៣៣**គោលដៅ មនុស្សចំនួន ៨៤១នាក់ (ស្រី **៦៣៥**នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន ១៥លើក។

### ៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

▪ ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ ចំនួន ១១៨នាក់(ស្រី១២នាក់) មាន ២០សញ្ជាតិ។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមរយៈទូរស័ព្ទ ចំនួន ០២នាក់(ស្រី) មានសេចក្ដីសុខជម្មតា។

### ៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តក្រចេះ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារនៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ចំនួន ០១លើក។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត បានចុះណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រ សហគ្រាស កន្លែងលាងឡាន និងកន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឪពុកម្ដាយកុមារតូចអាយុ ០ឆ្នាំដល់៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅមួយចំនួន។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៥ករណី(ធៀបនឹងខែកក្កដា មានចំនួន ១៥ករណី ស្មើគ្នា) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២០នាក់(ស្រី០២នាក់) ក្នុងនោះជនជាតិចិន ០៣នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៣៧នាក់(ស្រី៣៤នាក់) មាន៖ អាយុក្រោម១៥ឆ្នាំ ១០នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុ១៨ឆ្នាំឡើង ១៨នាក់ (ប្រគល់ឱ្យសង្គមកិច្ច ២៣នាក់ និងប្រគល់ឱ្យគ្រួសារ ១៤នាក់) ក្នុងនោះ បែកជា៖

✧. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០២ករណី/០៤ករណី (ថយ ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៤នាក់(ចិន ០៣នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ០៣នាក់(ស្រី០១នាក់) មាន៖ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០២នាក់ (ប្រគល់ឱ្យគ្រួសារ ០៣នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១ | ០១ | ០១ | |
| -អំពើលក់ដូរមនុស្ស | ០១ | ០២ | ០៣ | ចិន៣ |
| *សរុប* | *០២ ករណី* | *០៣ នាក់* | *០៤ នាក់* | *០៣ នាក់* |

❖. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៣ករណី/១១ករណី (កើនឡើង ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៦នាក់ (ស្រី០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៣៤នាក់(ស្រី៣៣នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ១០នាក់ និងអាយុ ១៥-១៧ឆ្នាំ ០៨នាក់ និងអាយុ១៨ឆ្នាំឡើង ១៦នាក់ (ប្រគល់ឱ្យសង្គមកិច្ច ២៣នាក់ ប្រគល់ឱ្យគ្រួសារ ១១នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ២៣ | ០៤ |
| -រូបភាពនិងសម្ភារៈអាសអាភាស | ០១ | ០១ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | ០៥ |
| -អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ | ០៦ |
| *សរុប* | *១៣ ករណី* | *៣៤ នាក់* | *១៦ នាក់* |

## **ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ**

### **១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ**

#### **១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ៤.៧២៧នាក់(ស្ត្រី១.៩៦៩នាក់) កុមារ៥១៨នាក់(កុមារី ២៨៨នាក់) សកម្មភាពមានដូចជាៈ

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ** បានទទួលចំនួន ២០នាក់ (ស្ត្រី ០៤នាក់) មកពីប្រទេសចិន ០៣នាក់ ម៉ាឡេស៊ី ០៣នាក់ និងថៃ ១៤នាក់ ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ០៣នាក់ ជួញដូរកម្លាំងពលកម្ម ១៤នាក់ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ០៣នាក់ បន្ទាប់ពីបានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។
- **មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពីប្រទេសថៃចំនួន ៤.៧០៧នាក់ (ស្ត្រី ១.៩៦៥នាក់)កុមារ ៥១៨នាក់ (កុមារី ២៨៨នាក់) បានសម្ភាសកំណត់អត្តសញ្ញាណរកឃើញមុខសញ្ញាជនរងគ្រោះ ជនងាយរងគ្រោះ និងកុមារមិនមានមនុស្សអមដំណើរមកជាមួយ និងផ្តល់ការស្នាក់នៅរយៈពេលខ្លីក្នុងមណ្ឌលសំចតមុនពេលបញ្ជូនទៅទទួលសេវាស្នាក់នៅបន្តនៅអង្គការដៃគូ។

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន ១៤នាក់(ស្រី ១៣នាក់) អនីតិជន ០១នាក់ មកពីប្រទេសចិន ១២នាក់(ស្រី) អនីតិជន ០១នាក់ និងម៉ាឡេស៊ី ០២នាក់(ស្រី០១នាក់)។ ជាលទ្ធផលរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈទៅចិន ១២នាក់(ស្រី) អនីតិជន ០១នាក់ និងស្នាក់នៅដោយខុសច្បាប់ ០២នាក់(ស្រី០១នាក់)។

- **ខេត្តបន្ទាយមានជ័យ៖** ស្នងការនគរបាលខេត្ត ពលករចូលតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ៧៣លើក មនុស្សចំនួន ៥.០៥៥នាក់ (ស្រី ២.១២៥នាក់) អនីតិជន ៧០២នាក់។
- **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០៣លើក មនុស្សចំនួន ០៣នាក់។
- **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ០១លើក មនុស្សចំនួន ២៥នាក់(ស្រី១៥នាក់) អនីតិជន ១៦នាក់។

### ២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ៣៤៤នាក់ កុមារ ៣៤៤នាក់(កុមារី ១៦៩នាក់) ក្នុងនោះបានមកពីអង្គការមូលនិធិA21 ០៤នាក់ អង្គការអាហ្វ៊ីស៊ីបកម្ពុជា **១៧៦**នាក់ និងសមាគមកុមាររីករាយ ១៦៤នាក់។ ជាករណីរំលោភបំពានផ្លូវភេទ ១៤៨នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០១នាក់ ជួញដូរតាមប្រព័ន្ធអនឡាញ ០១នាក់ និងងាយរងគ្រោះ ១៧៦នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ខេត្តស្វាយរៀង៖**<br>-លេខាធិការដ្ឋាន គ.ឧ.ប.ជ សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការគ្រប់គ្រងករណី និងប្រព័ន្ធបញ្ជូនបន្ត។ | ១ | ២៥ | ១៥ |
| -មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សហការជាមួយក្រុមហ៊ុនចំនួន៧ បានបើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ។ | ៩ | ១៤២ | ៨៩ |
| **ខេត្តសៀមរាប៖**<br>-**អង្គការមូលនិធិអ២១៖** បណ្តុះបណ្តាលស្តីពី កម្មវិធីហ្គេមយល់ដឹងអំពីការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយសុវត្ថិភាព និងការការពារកុមារពីការកេងប្រវ័ញ្ចផ្សេងៗលើប្រព័ន្ធអនឡាញ។ | ០២ | ៨០ | ៤៥ |
| **ខេត្តព្រះវិហារ៖** មន្ទីរសុខាភិបាល សហការជាមួយអង្គការអាដ្រា បើកវគ្គបណ្តុះបណ្តាលស្តីពី គោលនយោបាយជាតិសុខភាពជនទេសន្តរប្រវេសន៍។ | ០១ | ៣០ | ១៧ |
| **ខេត្តព្រៃវែង៖** គ.ឧ.ប.ជ សហការជាមួយអង្គការជំនួយផ្លូវច្បាប់កុមារនិងស្ត្រី បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការគ្រប់គ្រងករណី និងប្រព័ន្ធបញ្ជូនបន្ត។ | ០១ | ២០ | ១០ |
| **សរុប** | **១៤ វគ្គ** | **២៩៧ នាក់** | **១៧៦ នាក់** |

២. សិក្ខាសាលា

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ សហការជាមួយ IOM បើកសិក្ខាសាលា ស្ដីពីប្រសិទ្ធភាពនៃកម្មវិធីជំនួយត្រឡប់ និងសមាហរណកម្មឡើងវិញនៅកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា មានអ្នកចូលរួមសរុបចំនួន ៤៧រូប ស្រី ២០រូប ។
- ខេត្តព្រៃវែង៖ មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយរដ្ឋបាលខេត្ត ក្រោមការឧបត្ថម្ភដោយអង្គការ IOM បានរៀបចំសិក្ខាសាលាស្ដីពី ការគ្រប់គ្រងករណីវិលត្រឡប់ និងសមាហរណកម្ម មានសិក្ខាកាម ៣១នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
បានរៀបចំកិច្ចប្រជុំផ្លូវការបាយការណ៍ ស្ដីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត ក្រោមអធិបតីភាព **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ**។

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖
  - ដឹកនាំកិច្ចប្រជុំពិភាក្សាបន្ត ស្ដីពីការត្រៀមរៀបចំកម្មវិធីវេទិកាផ្សព្វផ្សាយអន្តរសាសនា ឆ្នាំ២០២២។
  - ដឹកនាំកិច្ចប្រជុំពិភាក្សា ដើម្បីលើកឡើងពីការព្រួយបារម្ភរបស់អង្គការសហប្រជាជាតិ អំពីការកើនឡើងនូវបញ្ហាជួញដូរមនុស្សនៅកម្ពុជា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងតំណាងអង្គការសហប្រជាជាតិនៅកម្ពុជា។
  - ដឹកនាំគណៈប្រតិភូនៃប្រទេសកម្ពុជាដែលជាសមាជិក គ.ជ.ប.ជ ទៅប្រជុំទ្វេភាគី រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្ដីពីការពិនិត្យមើលនីតិវិធីប្រតិបត្តិស្តង់ដារ ស្ដីពីកិច្ចសហប្រតិបត្តិការនៃការអនុវត្តច្បាប់រវាងប្រទេសថៃ-កម្ពុជា នៅសណ្ឋាគារ Sukosol ទីក្រុងបាងកក ប្រទេសថៃ ដោយសហការរៀបចំឡើងដោយអង្គការ IOM។

### ២. ការងារជំនួបពិភាក្សា

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន៖
    - ទទួលជួបតំណាងបេសកកម្មអង្គការ JICA ដឹកនាំដោយ លោកស្រី Uchikawa Tomomi ប្រធានជាន់ខ្ពស់ នៃការិយាល័យលើកកម្ពស់សមភាពយេនឌ័រ និងកាត់បន្ថយភាពក្រីក្រ និងជាប្រធានដឹកនាំការអនុវត្តគម្រោង និងសហការី នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
    - បានទទួលជួបពិភាក្សាការងារ ជាមួយ កញ្ញា Kristen Scharf អ្នកគ្រប់គ្រងរបស់អង្គការ A២១ ប្រចាំប្រទេសកម្ពុជា លោក **រស់ យ៉េង** ប្រធានមជ្ឈមណ្ឌល តស៊ូមតិសម្រាប់កុមារ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ បានជួបពិភាក្សាការងារជាមួយ ក្រុមការងារនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ពិភាក្សារៀបចំផែនការសកម្មភាព ដើម្បីជួយគាំទ្រ ដល់ជនរងគ្រោះពីការជួញដូរមនុស្ស។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារជាមួយទីប្រឹក្សាបច្ចេកទេសអង្គការ ISSARA ពិភាក្សាអំពីបញ្ហាប្រឈមរបស់ពលករធ្វើការនៅប្រទេសថៃ។

### គ. ការខារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៨៥លើក មានអ្នកចូលរួមសរុប ១.២៦០នាក់(ស្រី ៦៤១នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២៥លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៦លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ៥៤លើក។(ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែកញ្ញា ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ.........ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ-ម៉ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៨៥លើក) មនុស្សចំនួន ១.២៦០នាក់ (ស្រី ៦៤១នាក់)

| ស្ថាប័ន<br>សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>(គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ជាអធិបតីភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន នៅខេត្តព្រះសីហនុ ដោយមានកិច្ចសហការជាមួយអង្គការ ASEAN-ACT និង UNICEF ចំនួន ០២លើក។<br>- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំ ពិភាក្សាស្តីពីវឌ្ឍនភាព នៃដំណើរការមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ចូលរួមកិច្ចប្រជុំពិភាក្សាបន្ត ស្តីពីការត្រៀមរៀបចំកម្មវិធីវេទិកាផ្សព្វផ្សាយអន្តរសាសនា ឆ្នាំ២០២២ នៅសាលប្រជុំ គ.ជ.ប.ជ។<br>- ចូលរួមពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តព្រះសីហនុ ដោយសហការជាមួយ ASEAN-ACT។<br>- អមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ធ្វើជាវាគ្មិនកិត្តិយសក្នុងសន្និសិទសារព័ត៌មានស្តីពី ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៣១ច្បាប់ លិខិតចូល ១៦ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៨ច្បាប់ លិខិតចូល ១៧ច្បាប់។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែសីហា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន១៣០ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន២៨សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ២១ច្បាប់។ |

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - លោកឧត្តមសេនីយ៍ទោ រ៉ន សុក័ក្រវ៉ឌ្ឍនា ប្រធានក្រុម បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តព្រះសីហនុ ចំនួន ០២លើក។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - បានចូលរួមបើកសិក្ខាសាលាវគ្គបណ្តុះបណ្តាល និងបញ្រ្ជាបការយល់ដឹងអំពីសុខភាពជនទេសន្តរប្រវេសន៍ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពនៅខេត្តកំពង់ធំ មានអ្នកចូលរួម ៣០នាក់ ស្រី០៦នាក់ ក្រោមការឧបត្ថម្ភដោយអង្គការADRA។
  - បានចូលរួមបើកសិក្ខាសាលាបណ្តុះបណ្តាលស្តីពី គោលការណ៍ណែនាំ នីតិវិធីក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តព្រះសីហនុ មានសិក្ខាកាមចូលរួម៤០នាក់ ស្រី១៣នាក់។
  - បានចូលរួមជាគ្រូឧទ្ទេសសម្របសម្រួលក្នុងសិក្ខាសាលា ស្តីពី គោលនយោបាយជាតិសម្រាប់សុខភាពជនទេសន្តរប្រវេសន៍ នៅខេត្តព្រះវិហារ មានសិក្ខាកាមចូលរួម២២នាក់ ស្រី១១នាក់។
  - បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស គណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាង គោលការណ៍ណែនាំ ស្តីពីកិច្ចការការពារកុមារតាមប្រព័ន្ធអនឡាញ ក្រោមជំនួយគាំទ្រដោយអង្គការ PLAN នៅមន្ទីរស.អ.យ ខេត្តកំពត។
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីបញ្ហាប្រឈម និងភាពធន់របស់ស្ត្រីចំណាកស្រុកកម្ពុជា ក្នុងអំឡុងពេលកូវីដ-១៩ នៅសណ្ឋាគារសាន់វេ ភ្នំពេញ មានអ្នកចូលរួម ៣០នាក់ ស្រី១៤នាក់។
- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - បានចូលរួមជាគ្រូបង្គោលបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្រ្តីជួរមុខ ស្តីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន នៅខេត្តព្រះសីហនុ ក្រោមជំនួយឧបត្ថម្ភដោយអង្គការមូលនីធិអប់រំកុមារអង្គការសហប្រជាតិ(UNICEF)។
  - បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី ការបារម្ភរបស់អង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅកម្ពុជា។
  - បានចូលរួមកិច្ចប្រជុំទ្វេភាគី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្តីពី ការពិនិត្យមើលនីតិវិធីប្រតិបត្តិស្តង់ដា និងកិច្ចសហប្រតិបត្តិការ នៃការអនុវត្តច្បាប់ រវាងប្រទេសថៃ-កម្ពុជា និងពិធីចុះហត្ថលេខាលើឯកសានីតិវិធីប្រតិបត្តិស្តង់ដា SOP នៅសណ្ឋាគារ Sukosol ទីក្រុងបាងកក ប្រទេសថៃ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - បានចូលរួមក្នុងជំនួបតំណាងបេសកកម្ម របស់អង្គការ JICA ដឹកនាំដោយ លោកស្រី យូឈីកាវ៉ា តូម៉ូមី (Uchikawa Tomomi) ប្រធាន ជាន់ខ្ពស់នៃការិយាល័យលើកកម្ពស់សមភាពយេនឌ័រ និងកាត់បន្ថយភាពក្រីក្រ និងជាប្រធានដឹកនាំការអនុវត្តគម្រោង និងសហការី ស្តីពីគម្រោងផែនការសកម្មភាព នៃការអភិវឌ្ឍសមត្ថភាពក្នុងការប្រឆាំងការជួញដូរមនុស្ស របស់JICA នៅសាលប្រជុំ គ.ជ.ប.ជ។

| | |
|---|---|
| | - បានបន្តវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលស្តីពីមូលដ្ឋានគ្រឹះ នៃការសរសេរកូដកម្មវិធី (HTML) ជូនដល់ក្រុមជំនួយកិច្ចការទាំង៦ និងក្រុមការងារលេខាធិការដ្ឋាន មានចំនួនសរុប ០៦នាក់ ស្រី០១នាក់។<br>- បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ និងការកំណត់ អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន សម្រាប់ក្រុមទី២ នៅខេត្តព្រះសីហនុ ដោយសហការជាមួយអង្គការយូនីសេហ្វ( UNICEF) មានអ្នកចូលរួមសរុប ៦០នាក់ ស្រី១៨នាក់។<br>- បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញស្តីពី ការអនុវត្តគោលការណ៍មិនដាក់ពិន័យទោសទៅលើជនល្មើសទាំងឡាយណា ដែលជាជនរងគ្រោះក្នុងអំពើជួញដូរមនុស្ស ក្នុងក្របខណ្ឌអាស៊ាន។ កិច្ចប្រជុំដឹកនាំដោយក្រុមការងារ PROSPECT ASEAN សហការដោយ ASEAN-ACT និង USAID មានអ្នកចូលរួមប្រមាណ ២៥នាក់។<br>- បានអញ្ជើញជាអធិបតី បើក និងបិទវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមទី១ ស្តីពី កិច្ចការពារកុមារ និង ការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានសហការជាមួយអង្គការយូនីសេហ្វ( UNICEF) នៅខេត្តព្រះសីហនុ អ្នកចូលរួមសរុប ៦១នាក់ ស្រី២៦នាក់។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរវិស័យអាស៊ាន ស្តីពីផែនការការងារពហុវិស័យប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២-២០២៧ ដែលបានរៀបចំឡើងដោយប្រទេសហ្វីលីពីន តាមរយៈប្រព័ន្ធអនឡាញ។<br>- បានចូលរួមជួបពិភាក្សាការងារជាមួយ កញ្ញា Kristen Scharf អ្នកគ្រប់គ្រងរបស់អង្គការ A២១ ប្រចាំប្រទេសកម្ពុជា។<br>- បានអញ្ជើញអមដំណើរ គណៈប្រតិភូប្រទេសកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីការពិនិត្យមើលនីតិវិធីប្រតិបត្តិ ស្តង់ដាស្តីពីកិច្ចសហប្រតិបត្តិការនៃការអនុវត្តច្បាប់ រវាងប្រទេសថៃ-កម្ពុជា និងពិធីចុះហត្ថលេខាលើឯកសានីតិវិធីប្រតិបត្តិស្តង់ដា SOP នៅសណ្ឋាគារ Sukosol ទីក្រុងបាងកក ប្រទេសថៃ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- បានចូលរួមសិក្ខាសាលាត្រីភាគីសម្រាប់វេទិកាអាស៊ានលើកទី១៥ ស្តីពីការបើកដំណើរការឡើងវិញនៃទេសន្តរប្រវេសន៍ការងារ និងសហប្រតិបត្តិការក្នុងតំបន់ នៅសណ្ឋាគារភ្នំពេញ។<br>- បានចូលរួមប្រជុំស្តីពី ប្រសិទ្ធភាពនៃកម្មវិធីជំនួយក្នុងការវិលត្រឡប់ដោយស្ម័គ្រចិត្ត និងការធ្វើសមាហរណកម្មនៅកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា ដែលរៀបចំឡើងដោយអង្គការ IOM ប្រចាំនៅកម្ពុជា។<br>- ឯកឧត្តម **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង បានសម្ភាសន៍ជាមួយអង្គការ IOM ប្រចាំនៅកម្ពុជា ស្តីពីការវិភាគលើចំណុចខ្វះខាតក្នុងច្បាប់ ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រ ក្នុងប្រទេសកម្ពុជា ធៀបនឹងស្តង់ដារការងារអង្គការអន្តរជាតិ តាមប្រព័ន្ធអនឡាញ។ |

| | |
|---|---|
| | - ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សា និងផ្តល់យោបល់លើករណីរបស់ប្រទេសទួគី ស្នើសុំចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពី សហប្រតិបត្តិបណ្តុះបណ្តាល កងកម្លាំងអនុវត្តច្បាប់ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋទួគី នៅក្រសួងមហាផ្ទៃ។<br>- ចូលរួមសិក្ខាសាលាត្រីភាគីថ្នាក់ជាតិ ស្តីពីការត្រួតពិនិត្យប្រចាំឆ្នាំ លើកម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ នៅសណ្ឋាគារភ្នំពេញ រៀបចំដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់ (គ្មានសកម្មភាព)**<br>- |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចូលរួមប្រជុំជាមួយ គ.ជ.ប.ជ ០២លើក។<br>- បានចាត់មន្ត្រីជំនាញចូលរួមជាគ្រូបង្គោលវគ្គបណ្តុះបណ្តាល លើការគ្រប់គ្រងករណីក្នុងការវិលត្រឡប់ និងការធ្វើសមាហរណកម្ម នៅខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ កំពង់ចាម និងខេត្តព្រៃវែង ដែលឧបត្ថម្ភដោយអង្គការ IOM។<br>- បានចូលរួមសិក្ខាសាលាដែលរៀបចំដោយ គ.ជ.ប.ជ ០២វគ្គ។<br>- បានចូលរួមកម្មវិធីសន្និសីទសារព័ត៌មានស្តីពី ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី ០១លើក។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៥៤លើក អ្នកចូលរួមសរុបចំនួន ៩៨៦នាក់(ស្រី ៥៥២នាក់)** | |
| ខេត្តសៀមរាប | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក អ្នកចូលរួមចំនួន **៦១**នាក់ ស្រី**៣៥**នាក់។<br>- ប្រជុំក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រុង-ស្រុក ចំនួន០៨លើក អ្នកចូលរួមចំនួន **២១៧**នាក់ ស្រី**៨៥**នាក់។<br>- បានចូលរួមសិក្ខាសាលាស្តីពី ប្រសិទ្ធភាពនៃកម្មវិធីជំនួយក្នុងការវិលត្រឡប់ដោយស្ម័គ្រចិត្ត និងការធ្វើសមាហរណកម្មនៅកម្ពុជា ០១លើក នៅរាជធានីភ្នំពេញ។<br>- បានចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់មជ្ឈមណ្ឌលសេរីភាព របស់អង្គការមូលនិធិអេ២១ នៅខេត្តសៀមរាប។<br>- បានប្រជុំពិភាក្សាការងារជាមួយអង្គការមូលនិធិអេ២១ ស្តីពីការត្រៀមរៀបចំព្រឹត្តិការណ៍បញ្ឈប់អំពើជួញដូរមនុស្ស ០១លើក នៅសាលាខេត្ត។ |
| ខេត្តកណ្តាល | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក មានអ្នកចូលរួម **២៧**នាក់ ស្រី១៨នាក់។<br>- ក្រុមការងារក្រុង ស្រុក-ប្រជុំប្រចាំខែ ចំនួន០៥លើក អ្នកចូលរួម **១៦៩**នាក់ ស្រី៨១នាក់។ |
| ខេត្តកំពង់ចាម | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពី "សកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមាររាល់ទម្រង់នៃការកេងប្រវ័ញ្ច" រៀបចំដោយនាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី នៅខេត្តស្ទឹងត្រែង ០១លើក។ |

| | |
|---|---|
| | - លោកជំទាវ **ប៉ាង ដានី** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមសិក្ខាសាលាស្តីពី“ការគ្រប់គ្រងករណីនៃការវិលត្រឡប់របស់ពលករទេសន្តរប្រវេសន៍” ក្រោមអធិបតីឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគាLBN មានអ្នកចូលរួមសរុប ៣៨នាក់ ស្រី១៨នាក់។ |
| **ខេត្តព្រៃវែង** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ និងឆមាស ចំនួន០២លើក មានអ្នកចូលរួម **៧៦**នាក់ ស្រី៣៨នាក់។<br>- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផែនការប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ ចំនួន ០២លើក ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។ |
| **ខេត្តកោះកុង** | - ស្នងការរងទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងនាយការិយាល័យជំនាញ បានចូលរួមកិច្ចប្រជុំស្តីពី «ការស្រាវជ្រាវបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ» ក្រោមអធិបតីភាពលោកជំទាវ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ នៅនាយកដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។<br>- លោកជំទាវ **មិថុនា ភូថង** អភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ ខេត្ត បានចូលរួមកិច្ចប្រជុំស្តីពី «ការងារអនុវត្តផែនការបង្ក្រាបការជួញដូរមនុស្ស» ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| **ខេត្តកំពង់ឆ្នាំង** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក។ |
| **ខេត្តមណ្ឌលគិរី** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ និងប្រចាំខែ ០១លើក។<br>- ចូលរួមកិច្ចប្រជុំពិភាក្សាលើការងាររៀបចំផែនការកិច្ចការពារកុមារខេត្តមណ្ឌលគិរី និងប្រកាសសមាភាពក្រុមការងារកិច្ចការពារកុមារខេត្តមណ្ឌលគិរី។ |
| **ខេត្តត្បូងឃ្មុំ** | - មន្ត្រីជំនាញ នៃមន្ទីរកិច្ចការនារី បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ |
| **ខេត្តបន្ទាយមានជ័យ** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ នៅទីស្តីការក្រសួង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពង់ **សម្តេចក្រឡាហោម ស ខេង ឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។<br>- បានចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពី ការគ្រប់គ្រង់ការវិលត្រលប់សមាហរណកម្មសម្រាប់ថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធ ០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីប៉ូលីស និងអ្នកផ្តល់សេវា ក្នុងការបង្កើនការចូលរួមសមស្របជាមួយជនរងគ្រោះក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីពលករចំណាកស្រុក និងការប្រមូលទិន្នន័យប្រកបដោយគុណភាព នៅខេត្តសៀមរាប ០១លើក។<br>- បានចូលរួមប្រជុំសម្របសម្រួល ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្រោមអធិបតីភាព ឯកឧត្តម **ឈួរ សុបញ្ញា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃម.ជ.ជ នៅសាលាក្រុងប៉ោយប៉េត។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីបង្កើតផែនការវិស័យកិច្ចការការពារកុមារខេត្ត បីឆ្នាំរំកិល(២០២៣-២០២៥) នៅសាលាខេត្តបន្ទាយមានជ័យ។ |

| | |
|---|---|
| | - បានចូលរួមជាគ្រូបង្គោលក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងករណីក្នុងការវិលត្រឡប់ និងសមាហរណកម្ម សម្រាប់អ្នកផ្តល់សេវាជូនដល់មន្ត្រីថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធ ០២លើក នៅខេត្តសៀមរាប និងបន្ទាយមានជ័យ។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ ផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារT27 ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីវឌ្ឍនភាពនៃដំណើរការមណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** នៅសាលប្រជុំសាលាខេត្តបាត់ដំបង។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងករណីក្នុងការវិលត្រឡប់ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារក្លាស់ស៊ី & ស្ប៉ា ខេត្តបាត់ដំបង ។<br>- មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានចូលរួមចុះផ្សព្វផ្សាយអំពីទេសន្តរប្រវេសន៍ ជូនដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ឃុំតាក្រី និងឃុំតាសែន ស្រុកកំរៀង ចំនួន ០៨លើក ដែលមានអ្នកចូលរួមចំនួន **២៧១**នាក់ ស្រី១៨០នាក់ ដែលរៀបចំដោយមណ្ឌលទទួលពលករកំរៀង ។ |
| **ខេត្តកំពង់ស្ពឺ** | - បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបង្កើនការចូលរួមសមស្របសម្រាប់មន្ត្រីនគរបាល និងអ្នកផ្តល់សេវា ពាក់ព័ន្ធក្នុងការឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងពលករចំណាកស្រុកជាស្ត្រី និងការប្រមូលទិន្នន័យប្រកបដោយគុណភាព ចំនួន**០៥**លើក សរុបអ្នកចូលរួម**១២៧**នាក់ ស្រី**៩៧**នាក់។ |